មូលនិធិខ្មែរសម្រាប់ការសិក្សា
Cambodian Education Excellence Foundation
ផ្តល់លទ្ធភាពសិក្សាស្មើភាពគ្នា Equal Education Opportunity for All.
12739 Knightsbridge Drive, Woodbridge, VA 22192. Tel: (703) 670-0854. ceefusa@ceefoundation.org www.ceefoundation.org

# សេចក្តីប្រកាសព័ត៌មាន

## ពិធីផ្តល់អាហារូបករណ៍ដល់និស្សិតក្រីក្រ និងរៀនពូកែ

## ដែលប្រារព្ធធ្វើឡើងនៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា

## ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៧

**ភ្នំពេញ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៧៖** មូលនិធិខ្មែរសំរាប់ការសិក្សា គ្រោងនឹងរៀបចំពិធីផ្តល់អាហារូបករណ៍សំរាប់ឆ្នាំសិក្សា ២០០៧-២០០៨ ទៅដល់និស្សិតក្រីក្រ និងរៀនពូកែ ចំនួន២៨នាក់ ដែលមកពីបណ្តាសាកលវិទ្យាល័យធំៗចំនួនប្រាំ នៅទីក្រុងភ្នំពេញ មានសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច សាកលវិទ្យាល័យភូមិន្ទភ្នំពេញ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា សាកលវិទ្យាល័យបញ្ញាសាស្ត្រ និងសាកលវិទ្យាល័យបៀលប្រាយ។ និស្សិតដែលទទួលអាហារូបករណ៍ គឺជាអតីតសិស្សដែលមកពីខេត្តមួយចំនួន ដូចជា បាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កណ្តាល ភ្នំពេញ ព្រៃវែង តាកែវ បន្ទាយមានជ័យជាដើម ដែលត្រូវបានជ្រើសរើសក្នុងចំណោមបេក្ខជនចំនួន៦៣រូប ដែលបានដាក់ពាក្យសុំមក មូលនិធិខ្មែរសំរាប់ការសិក្សា។ និស្សិតទាំងនោះ បច្ចុប្បន្ន កំពុងបន្តការសិក្សាផ្នែកបរិញ្ញាប័ត្រច្បាប់ សេដ្ឋកិច្ច គណនេយ្យ ព័ត៌មានវិទ្យា វិទ្យាសាស្ត្រកុំព្យូទ័រ ពាណិជ្ជកម្មអន្តរជាតិ និងជំនាញផ្សេងៗទៀត។

មូលនិធិខ្មែរសំរាប់ការសិក្សា គឺជាអង្គការមនុស្សធម៌ ដែលមិនស្វែងរកប្រាក់ចំណេញ ត្រូវបានបង្កើតឡើងនៅក្នុងខែមេសា ឆ្នាំ២០០៧ ដែលមានមូលដ្ឋាននៅសហរដ្ឋអាមេរិក ក្នុងគោលបំណងធ្វើអោយប្រសើរឡើងនូវការសិក្សារបស់និស្សិតក្រីក្រ តាមរយៈការផ្តល់នូវជំនួយផ្នែកហិរញ្ញវត្ថុ។ បាវចនារបស់មូលនិធិ គឺ ***ផ្តល់លទ្ធភាពសិក្សាស្មើភាពគ្នា*** ហើយទស្សនៈរបស់យើងឈរនៅលើមូលដ្ឋានគ្រឹះចំនួនបួនគឺ៖ ***ភាពជាអ្នកប្រាជ្ញ*** - ការប្តេជ្ញាចិត្តក្នុងការសិក្សា, ***អត្ថប្រយោជន៍*** -ឱកាសក្នុងការជួយគ្នាទៅវិញទៅមក, ***ភាពជាអ្នកដឹកនាំ*** - គុណភាពក្នុងការផ្តួចផ្តើមគំនិត និង ***ចរិយាសម្បត្តិ*** - អនុភាពដែលញែកបុគ្គលម្នាក់ពីអ្នកដទៃ។

មូលនិធិ នេះ ត្រូវបានផ្តើមបង្កើតឡើងដោយប្រជាពលរដ្ឋខ្មែរ-អាមេរិក ដែលរស់នៅសហរដ្ឋអាមេរិក ហើយបានទទួលគាំទ្រពីប្រជាពលរដ្ឋនៅប្រទេសកាណាដា បារាំង និងកម្ពុជា។ ក្រុមប្រឹក្សាភិបាល ប្រធាន គណៈកម្មាធិការ និងសមាជិកនៃអង្គការ

នេះ គឺជាអ្នកស្ម័គ្រចិត្ត ដែលមានជំនឿរួមគ្នា ក្នុងការធ្វើការជួយដល់សិស្ស និស្សិតក្រីក្រ ដើម្បីអោយទទួលបាននូវការសិក្សាខ្ពស់ នៅប្រទេសកម្ពុជា។ ពួកយើងមិនគិតរកកំរៃ ឬថវិកាតបស្នងនោះទេ។ ការចំណាយរបស់យើង មានកំរិតតិចជាអប្បបរមា ដែលជាមូលហេតុធ្វើអោយធនធានស្ទើរតែទាំងអស់របស់**មូលនិធិ** អាចយកទៅបែងចែកសម្រាប់គាំទ្រដល់តំរូវការផ្នែកហិរញ្ញវត្ថុរបស់និស្សិតក្រីក្រ និងគាំទ្រដល់កម្មវិធីសិក្សាអប់រំផ្សេងៗទៀត។

**មូលនិធិខ្មែរសំរាប់ការសិក្សា** បានទទួលជំនួយពីបុគ្គលនិងអង្គការខ្មែរនានា នៅសហរដ្ឋអាមេរិក និងកាណាដា។ **មូលនិធិ**ត្រូវការវិភាគទាននិងជំនួយផ្នែកហិរញ្ញវត្ថុពីប្រទេសកម្ពុជា និងបណ្តាប្រទេសផ្សេងៗបន្ថែមទៀត ដើម្បីបំពេញនូវតំរូវការជួយឧបត្ថម្ភទៅដល់សិស្ស និងនិស្សិតខ្មែរដែលក្រីក្រ។ យើងសូមស្វាគមន៍យ៉ាងកក់ក្តៅនូវការគាំទ្រផ្នែកហិរញ្ញវត្ថុ ពីសំណាក់សប្បុរសជនទាំងឡាយ។ ដើម្បីជ្រាបជាបន្ថែម អំពី **មូលនិធិខ្មែរសំរាប់ការសិក្សា** សូមចូលទៅកាន់គេហទំព័ររបស់យើងនៅ http://www.ceefoundation.org/.

**ទំនាក់ទំនង**


**សហរដ្ឋអាមេរិក៖** វេជ្ជបណ្ឌិត ខ្ញៅសំរ៉ង ប្រធាន**មូលនិធិខ្មែរសំរាប់ការសិក្សា**

- អ៊ីមែល៖ khunsamrang@gmail.com
- ទូរស័ព្ទ៖ ៥១៦-៩៧៤-៩៦១៦

កម្ពុជា៖ លោក អ៊ុំ សង់អុន

- អ៊ីមែល៖ samoum@cmac.org.kh / samoum@citylink.com.kh /

កញ្ញា ស្រ៊ិនដាវី

- អ៊ីមែល៖ davy.srin@austcare.org.kh
- ទូរស័ព្ទ៖ ០១២ ២២០ ២១២